# ប្រការគួរជៀសវាងសម្រាប់បុគ្គលិក អិលអូអិលស៊ី

បុគ្គលិក ៖

## A. មុនពេលទម្លាក់កម្ចី (Pre-Disbursement)

1. មិនត្រូវធ្វើការផ្សព្វផ្សាយដែលមានលក្ខណៈ**បោកបញ្ឆោត បំភាន់ ឬបង្ខំអតិថិជនឡើយ**
2. មិនត្រូវបញ្ចុះបញ្ចូលអតិថិជនអោយស្នើប្រាក់កម្ចីដែលលើសពីតម្រូវការជាក់ស្តែង
3. មិនត្រូវប្រមូលព័ត៌មានដោយមិនមាន ការអនុញ្ញាតពីអតិថិជន
4. មិនត្រូវផ្សព្វផ្សាយ/ផ្តល់ប្រាក់កម្ចីចំពោះអតិថិជនដែលមានមុខរបរស្ថិតក្នុងមុខរបរហាមឃាត់/ខុសច្បាប់ ។
5. មិនត្រូវបំប៉ោងចំណូល ឬបន្ថយចំណាយ ដើម្បីអោយអតិថិជនទទួលបានប្រាក់កម្ចីលើសពីសមត្ថភាពសង
6. មិនត្រូវផ្តល់ប្រាក់កម្ចីដោយសម្អាងទ្រព្យដាក់ធានា ប៉ុន្តែត្រូវផ្អែកលើសមត្ថភាពសងជាចំបង

## B. កំឡុងពេលទម្លាក់កម្ចី (During Disbursement)

1. មិនត្រូវផ្តល់ប្រាក់កម្ចី ពេលដឹងថាអតិថិជន មិនមានសមត្ថភាពសង
2. មិនត្រូវផ្តល់ប្រាក់កម្ចីថ្មី ឬផ្តល់ប្រាក់កម្ចីបន្ថែម ពេលដឹងច្បាស់ថា អតិថិជនកំពុងមានបំណុលដែលមានបញ្ហាជាមួយស្ថាប័នផ្សេង ឬអ្នកចងការប្រាក់ឯកជន
3. មិនពឹងផ្អែកលើអ្នកចងការប្រាក់ឯកជន ដើម្បីបង្កើតជាផ្នែកមួយនៃវដ្តបំណុល និងកាន់តែច្រើនឡើង
4. មិនផ្តល់ប្រាក់កម្ចីដែលបង្កអោយមាន ឬដឹងច្បាស់ថាមានការប្រើប្រាស់កម្លាំងពលកម្មកុមារដែលធ្វើអោយកុមារបាត់បង់ឱកាសចូលសាលា
5. មិនត្រូវផ្តល់ប្រាក់កម្ចីដោយមិនបានពន្យល់អតិថិជនអំពី៖ លក្ខខណ្ឌពិសេសនៃកិច្ចសន្យា និងការបណ្តុះវិន័យឥណទានឡើយ

## C. ក្រោយពេលទម្លាក់កម្ចី (Post-Disbursement)

1. មិនត្រូវគំរាមកំហែង ចង្អុលមុខ ជេរប្រមាថ ឈ្លោះប្រកែក ឬតបតដោយហិង្សា ចំពោះអតិថិជន អ្នកធានាបំណុល ឬសាច់ញាតិរបស់អតិថិជន/អ្នកធានាឡើយ
2. មិនត្រូវលូកលាន់រាងកាយ ឬហោប៉ាវខោអាវ ឬប្រើប្រាស់ពាក្យសម្តីអសុរស ឬពាក្យសម្តីប្រមាថមើលងាយចំពោះអតិថិជន/អ្នកធានា/សាច់ញាតិ ឬប្រើប្រាស់ពាក្យថា អិលអូអិលស៊ី មិនមែនជាអង្គការសប្បុរសធម៌ ឬជាអង្គការកាកបាទក្រហមឡើយ
3. មិនត្រូវបិទស្លាកលក់ លើដី/លំនៅដ្ឋាន ឬចាក់សោរផ្ទះ អតិថិជន/អ្នកធានាបំណុល
4. មិនត្រូវបិទកិច្ចសន្យាខ្ចីចងការប្រាក់ កិច្ចសន្យាបង្កើតហ៊ីប៉ូតែក ឬឯកសារផ្សេងៗ ទាក់ទងនឹងកូនបំណុល ឬអ្នកធានាបំណុល លើលំនៅដ្ឋានរបស់អតិថិជន/អ្នកធានា

5. មិនត្រូវរឹបអូសនូវចលនវត្ថុ ឬទ្រព្យសម្បត្តិ ផ្សេងៗ (ឡាន ម៉ូតូ កង់ ចានឆ្នាំង ទូរទស្សន៍ តុ ទូ គោ ក្របី ជ្រូក ជាដើម) របស់កូនបំណុល ឬអ្នកធានាបំណុលដោយផ្ទាល់ ឬប្រយោល ទោះបីជាមានការយល់ព្រមពីអតិថិជន ឬសាច់ញាតិ ឬអ្នកធានាបំណុលក៏ដោយ
6. មិនត្រូវធ្វើឱ្យខូចទ្រង់ទ្រាយដើម នៃទ្រព្យសម្បត្តិរបស់អតិថិជន ឬអ្នកធានា
7. មិនត្រូវទទួលយកចលនវត្ថុ របស់អតិថិជនមករក្សាទុកឡើយ ទោះបីជាមានការព្រមព្រៀងពីអតិថិជនក៏ដោយ
8. មិនត្រូវទទួលយកប្រាក់ទូទាត់បំណុល ដែលបានមកពីការលក់ទ្រព្យអតិថិជន ដោយខុសច្បាប់ពីសំណាក់ស្ថាប័នដទៃ
9. បុគ្គលិក ឬសាច់ញាតិរបស់បុគ្គលិក មិនត្រូវចូលរួម/ពាក់ព័ន្ធ ក្នុងការទិញ-លក់ ឬរឹបអូសទ្រព្យសម្បត្តិរបស់អតិថិជន/អ្នកធានាបំណុលឡើយ
10. មិនត្រូវញុះញង់/បញ្ជាឱ្យ អ្នកធានា/អាជ្ញាធរមូលដ្ឋាន ចូលយកចលនទ្រព្យ ឬអចលនទ្រព្យរបស់កូនបំណុល
11. មិនត្រូវចូលក្នុងបន្ទប់ ឬផ្ទះអតិថិជន ឬអ្នកធានាដោយគ្មានការអនុញ្ញាតវត្តមានអតិថិជន
12. មិនត្រូវប្រើប្រាស់មធ្យោបាយ អ៊ិលអូអ៊ិលស៊ី ឬមធ្យោបាយដែលអ៊ិលអូអ៊ិលស៊ីបានផ្តល់ ដើម្បីឱបអ្នកដទៃដូចជា៖ អតិថិជន អ្នកធានា សាច់ញាតិពាក់ព័ន្ធបំណុល ឈ្មួញ កណ្តាល ឬ អ្នកភូមិ ។ល។
13. មិនត្រូវបានលើកទឹកចិត្តឱ្យចុះជួបអតិថិជនពេលយប់ដោយគ្មានវត្តមានអាជ្ញាធរឡើយ
14. មិនត្រូវណែនាំ អតិថិជនអោយទៅខ្ចីប្រាក់ ពីអ្នកចងការប្រាក់ឯកជន ដើម្បីទូទាត់បំណុល
15. មិនត្រូវបង្ខំអតិថិជនអោយលក់ដី/ផ្ទះ ដោយការគម្រាមកំហែង បំភិតបំភ័យ បញ្ជា ដាក់សម្ពាធដោយផ្ទាល់។ ប៉ុន្តែបុគ្គលិកអាចជម្រាបអតិថិជនថា៖ «អ៊ិលអូអ៊ិលស៊ី នឹងអនុវត្តសិទ្ធិ របស់អ៊ិលអូអ៊ិលស៊ីតាមផ្លូវច្បាប់ និងតាមកិច្ចសន្យាលើទ្រព្យដាក់ធានា។»
16. មិនត្រូវបង្ខំអតិថិជនអោយលក់លំនៅដ្ឋានតែមួយគត់ដែលកំពុងអាស្រ័យផលសម្រាប់ជីវភាពជាចំបង។
17. មិនត្រូវដាក់សម្ពាធដោយនាំគ្នាច្រើន (លើសពី៣នាក់) ក្នុងការចុះដោះស្រាយបំណុលជាមួយអតិថិជន/អ្នកធានា៕

*សម្គាល់៖*

*បុគ្គលិកត្រូវគោរពតាមគោលការណ៍ និងនីតិវិធីផ្ទៃក្នុងរបស់អ៊ិលអូអ៊ិលស៊ី និងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។*